01335021
**Declassified to Public**
**12 June 2020**

លេខ៖ D323/1

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de réception): 11 / 10 / 2016
ម៉ោង (Time/Heure): 15:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦**

ភាសា ៖ **ខ្មែរ & អង់គ្លេស [អង់គ្លេស ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

---

# ដីកាសម្រេចលើសំណើបន្ទាន់ទាក់ទងនឹងការចូលពិនិត្យមើលសំណុំរឿង ០០៤

---

**ផ្ញើជូន ៖**

**សហព្រះរាជអាជ្ញា**

ជា លាង

Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**

មុំ លុដ្ឋ

Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**

សូ មូស្សេទ្ធី

Suzana TOMANOVIĆ

**អង្គភាពគាំពារការការពារក្តី**

Isaac ENDELEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉ែន ពៅ

Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

១.ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

២. តាមរយៈសំណើរបស់ខ្លួនចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៦ មេធាវីការពារក្តី អោ អាន(" មេធាវីការពារក្តី") ស្នើសុំ ស.ច.ស អនុញ្ញាតឱ្យលោក Benjamin Joyes ចូលពិនិត្យមើលសំណុំរឿង ០០៤ ក្នុងនាមជាអ្នកប្រឹក្សាច្បាប់មិនយកប្រាក់កម្រៃ នៅពេលដែលបញ្ចប់កិច្ចសន្យាការងារគាត់ជាអ្នកប្រឹក្សាច្បាប់យកប្រាក់កម្រៃ នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ហើយស្នើឱ្យអង្គភាពគាំពារការការពារក្តី ("អ.គ.ក") ចាត់វិធានការចាំបាច់ដើម្បីឱ្យគាត់អាចចូលពិនិត្យមើលឯកសារក្នុងប្រព័ន្ធការងាររបស់តុលាការ("សំណើ")[1]។

៣. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៦ ខ្ញុំបានផ្ញើអ៊ីមែលជូនទៅលោក Isaac Endeley ប្រធាន អ.គ.ក ដោយស្នើសុំ អ.គ.ក សម្របសម្រួលការអនុញ្ញាតឱ្យចូលពិនិត្យមើលឯកសារដូចដែលបានស្នើ បន្ទាប់ពីលោក Joyes បានចុះហត្ថលេខាលើទម្រង់ឯកសាររក្សាការសម្ងាត់តាមលក្ខខណ្ឌតម្រូវ។

៤. នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ លោក Isaac Endeley បានជូនដំណឹងខ្ញុំថា អ.គ.ក បានស្នើសុំជាផ្លូវការឱ្យបន្តការអនុញ្ញាតឱ្យលោក Joyes ចូលពិនិត្យមើលសំណុំរឿង ០០៤ និង Zylab ហើយក្រឡាបញ្ជីការិយាល័យសហចៅក្រមស៊ើបអង្កេត បានផ្ញើជូនលោក Joyes នូវឯកសារការងារចាំបាច់សម្រាប់ចូលពិនិត្យមើលឯកសារនេះ[2]។

---

[1]សំណុំរឿង ០០៤ ឯកសារ D323 *សំណើបន្ទាន់ទាក់ទងនឹងការចូលពិនិត្យមើលសំណុំរឿង* ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៦។

[2]ឧបសម្ព័ន្ធ ក៖ អ៊ីមែលពីលោក Isaac Endeley ផ្ញើជូនចៅក្រម Michael Bohlander *អំពីសំណើបន្ទាន់ទាក់ទងនឹងការចូលពិនិត្យមើលសំណុំរឿង-សំណោផ្តល់ជូន* ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦។

៥. នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៦ មេធាវីការពារក្តី បានផ្ញើអ៊ីមែលមកការិយាល័យរបស់ខ្ញុំ ដើម្បីបញ្ជាក់ថា លោក Joyes អាចចូលពិនិត្យមើលសំណុំរឿង និង Zylab ពីចម្ងាយបាន[3]។ ហេតុនេះ ការស្នើសុំនៅក្នុងសំណើរបស់មេធាវីការពារក្តី បានផ្តល់ជូនហើយ។

៦. ចាប់ពីពេលនេះតទៅ ខ្ញុំធ្វើកំណត់ហេតុជូនក្រុមមេធាវីការពារក្តីនៅក្នុងសំណុំរឿង 00៤ និង អ.គ.ក ថា ដោយស្របតាមដីកាសម្រេចពីមុនរបស់ខ្ញុំទាក់ទងនឹងមេធាវីការពារក្តី យឹម ទិត្យ[4] ខ្ញុំយល់ឃើញថាជាការសមស្របដែល អ្នកប្រឹក្សាធ្វើការមិនយកប្រាក់កម្រៃនៅក្រុមមេធាវីការពារក្តី ត្រូវទទួលបានការអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿងតាមរយៈ Zylab ក្នុងកម្រិតដូចគ្នានឹងអ្នកប្រឹក្សាច្បាប់ផ្សេងទៀតនៅក្នុងក្រុមមេធាវីការពារក្តី ហើយឱ្យចូលពិនិត្យមើលសំណុំរឿងតាមរយៈពេលដែលសហមេធាវីការពារក្តីស្នើសុំ។ ដូច្នេះ ខ្ញុំរំពឹងថា សំណើសុំចូលពិនិត្យមើលសំណុំរឿងនាពេលអនាគត នឹងត្រូវដោះស្រាយរវាងក្រុមមេធាវីការពារក្តីជាមួយនឹង អ.គ.ក ដោយមិនចាំបាច់ស្នើសុំការអនុញ្ញាតពី ស.ច.ស ឡើយ។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

៧. **កត់សម្គាល់** ថា សំណើបានដោះស្រាយហើយ ពីព្រោះថា ឥឡូវនេះ ការស្នើសុំនៅក្នុងសំណើរបស់មេធាវីការពារក្តី បានផ្តល់ជូនហើយ។

ភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**

---

[3]ឧបសម្ព័ន្ធ ខ៖ អ៊ីមែលពី Tibor Bajnovič ផ្ញើជូន Nivedha Thiru *អំពីសំណើបន្ទាន់ទាក់ទងនឹងការចូលពិនិត្យមើលសំណុំរឿង 00៤-* ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៦។

[4]សំណុំរឿង 00៤ ឯកសារ D312/4 *ដីកាសម្រេចទី ២ លើសំណើបន្ទាន់របស់ យឹម ទិត្យ ទាក់ទងនឹងធនធានបន្ថែមរបស់មេធាវីការពារក្តី* ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦ កថាខណ្ឌ ៨។